ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

លេខ : ១៤០៧/២៣ អ គ រ

ថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត

(Authorized Economic Operator Programme - AEO)

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានកិត្តិយសសូមជម្រាបជូនដល់សាធារណជន ឱ្យបានជ្រាបថា ដើម្បីចូលរួមអនុវត្តកាតព្វកិច្ចរបស់កម្ពុជាក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម និងដើម្បីលើកទឹកចិត្តដល់ធុរជនមានអនុលោមភាពខ្ពស់ ស្របតាមគោលនយោបាយពាណិជ្ជកម្មអន្តរជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាឧត្តមានុវត្តអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចដាក់ឱ្យអនុវត្ត " **កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត** " ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៣ នេះតទៅ។

**កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត** គឺជាកម្មវិធីមួយនៃភាពជាដៃគូរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានិងផ្នែកឯកជនដើម្បីសម្រួលពាណិជ្ជកម្មនិងធ្វើឱ្យប្រសើរឡើងនូវសន្តិសុខនិងសុវត្ថិភាពនៃខ្សែច្រវាក់ផ្គត់ផ្គង់សាកល។ តាមរយៈកម្មវិធីនេះ **ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត** នឹងទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗ និងការលើកទឹកចិត្តនានាជាច្រើនពីអគ្គ-នាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការអនុវត្តនីតិវិធីគយឬការបំពេញបែបបទគយ រួមទាំង អត្ថប្រយោជន៍ពីការចុះកិច្ចព្រមព្រៀងទទួលស្គាល់ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ទៅវិញទៅមក (Mutual Recognition Agreements - MRA) ជាមួយបណ្តាប្រទេសដៃគូនានានៅលើពិភពលោកផងដែរ។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបនិងស្ម័គ្រចិត្តចូលរួមកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតឱ្យបានច្រើនកុះករ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរសព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧០៥ សហវ.ប្រក.ពសស

# ប្រកាស

# ស្តីពី

# កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៤/០១៤ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រម លើការសុំចូលរួមជាភាគីហត្ថលេខីរបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងពិធីសារនៃវិសោធនកម្មអនុសញ្ញាអន្តរជាតិ ស្តីពីសាមញ្ញកម្មនិងសុខដុមនីយកម្មនីតិវិធីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០១ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មទៅក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងម៉ារ៉ាកេស



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh. Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៥២ សហវ.ប្រក.អគរ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីយន្តការលើកទឹកចិត្តដល់ធុរជនមានអនុលោមភាពខ្ពស់
- បានឃើញប្រកាសលេខ ១៦៣ សហវ.ប្រក.អគរ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋាន ក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.**_ គោលបំណង

ប្រកាសនេះកំណត់អំពីវិធាននិងនីតិវិធីសម្រាប់អនុវត្ត " **កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត**" (Authorised Economic Operator Programme - AEO) ដើម្បីផ្តល់កិច្ចសម្រួលពាណិជ្ជកម្មបន្ថែម និងរួមចំណែកបង្កើនសន្តិសុខនិងសុវត្ថិភាពនៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់សាកល។

**ប្រការ២.**_ វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះ បុគ្គលស្នើសុំការទទួលស្គាល់ជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត និងប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

**ប្រការ៣.**_ និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**កម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត** សំដៅដល់ កម្មវិធីលើកទឹកចិត្តធុរជនតាមរយៈការផ្តល់កិច្ចសម្រួលពាណិជ្ជកម្មបន្ថែមជូនបុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រកាសនេះនិងត្រូវបានទទួលស្គាល់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**កម្រងសំណួរវាយតម្លៃ** សំដៅដល់ សំណុំឯកសារនិងកម្រងសំណួរដែលបុគ្គលស្នើសុំត្រូវបំពេញ ដើម្បីជាមូលដ្ឋានសម្រាប់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាពិនិត្យផ្ទៀងផ្ទាត់ក្នុងការទទួលស្គាល់ជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

**ការផ្តល់សុពលភាព** សំដៅដល់ ការអនុវត្តនីតិវិធីគយចំពោះបុគ្គលស្នើសុំ ដើម្បីផ្ទៀងផ្ទាត់លក្ខណៈវិនិច្ឆ័យនៃការស្នើសុំទទួលស្គាល់ជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត រួមមាន ការពិនិត្យពាក្យស្នើសុំ ការវិភាគហានិភ័យ ការផ្ទៀងផ្ទាត់ឯកសារ ការត្រួតពិនិត្យវាយតម្លៃ នៅអាជីវកម្មដ្ឋានរបស់បុគ្គលស្នើសុំ និងការរៀបចំរបាយការណ៍នៃការរកឃើញ។

**ការអនុញ្ញាត** សំដៅដល់ ការទទួលស្គាល់ជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចំពោះបុគ្គលស្នើសុំទាំងឡាយណាដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យនិងបានទទួលការផ្តល់សុពលភាព ដូចមានចែងក្នុងប្រកាសនេះ។

**ដៃគូពាណិជ្ជកម្ម** សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលផ្តល់សេវានានា ដើម្បីបំពេញតម្រូវការរបស់ក្រុមហ៊ុនឬសហគ្រាសណាមួយនៅក្នុងពាណិជ្ជកម្មអន្តរជាតិ រួមមាន គ្រប់ភាគីដែលចូលរួមដោយផ្ទាល់ ឬដោយប្រយោល ក្នុងការទិញទំនិញ ការរៀបចំឯកសារ ការជួយសម្រួលផ្សេងៗ ការលើកដាក់ទំនិញ ការរក្សាទុកទំនិញ ការផ្ញើសន្និធិទំនិញ ការដឹកជញ្ជូនទំនិញ ក្នុងនាមប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

**បុគ្គលស្នើសុំ** សំដៅដល់ ប្រតិបត្តិករសេដ្ឋកិច្ចដែលស្នើសុំការអនុញ្ញាតទទួលស្គាល់តាមផ្លូវច្បាប់ពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមមាន អ្នកនាំចេញ អ្នកនាំចូល ជើងសាគយ សហគ្រាសផលិតកម្ម ប្រតិបត្តិករភស្តុភារកម្ម ប្រតិបត្តិករបញ្ជូនទំនិញ ប្រតិបត្តិករដឹកជញ្ជូនទំនិញ សហគ្រាសធុនតូចនិងមធ្យម និងនីតិបុគ្គលពាក់ព័ន្ធផ្សេងទៀត។

**ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត** សំដៅដល់ នីតិបុគ្គលដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រកាសនេះ និងត្រូវបានទទួលស្គាល់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**វិញ្ញាបនបត្រ** សំដៅដល់ វិញ្ញាបនបត្រប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

**អ្នកតំណាងបុគ្គលស្នើសុំ** សំដៅដល់ បុគ្គលដែលទទួលបានការផ្ទេរសិទ្ធិស្របច្បាប់ពីបុគ្គលស្នើសុំដើម្បីរៀបចំឯកសារដាក់ពាក្យស្នើសុំជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

**អ្នកនាំចេញ** សំដៅដល់ បុគ្គលដែលនាំចេញទំនិញដោយខ្លួនឯងឬដោយអ្នកដទៃ។ បុគ្គលដែលជាកម្មសិទ្ធិករនៃទំនិញ អ្នកផ្ញើទំនិញ អ្នកទទួលទំនិញ ភ្នាក់ងារ ឬឈ្មួញកណ្តាលដែលមានកម្មសិទ្ធិ ឬទទួលបានសិទ្ធិតាមវិធីណាក៏ដោយ ក្នុងការរក្សាទុកឬមើលការខុសត្រូវលើទំនិញដែលនាំចេញពីដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

**អ្នកនាំចូល** សំដៅដល់ បុគ្គលដែលនាំចូលទំនិញដោយខ្លួនឯង ឬដោយអ្នកដទៃ។ ត្រូវចាត់ជាអ្នកនាំចូលផងដែរនូវអ្នកទទួលទំនិញ បុគ្គលដែលជា ម្ចាស់កម្មសិទ្ធិ បុគ្គលដែលនឹងក្លាយទៅជាម្ចាស់កម្មសិទ្ធិ ឬអ្នកមានសិទ្ធិចាត់ចែងលើកម្មសិទ្ធិទំនិសញទាំងនោះ មុនពេលដែលទំនិញនោះលែងជាកម្មវត្ថុនៃការត្រួតពិនិត្យរបស់គយ។

**ឯកសារពាណិជ្ជកម្ម** សំដៅដល់ បច្ចុប្បន្នភាពនៃឯកសារពាក់ព័ន្ធនឹងការនាំចេញ ការនាំចូលការឆ្លងកាត់ ដែលត្រឹមត្រូវ គ្រប់គ្រាន់ និងអាចផ្ទៀងផ្ទាត់បានដោយមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច។

**ប្រការ៤._** ស្ថាប័នមានសមត្ថកិច្ច

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមាន នាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈ បំពេញមុខងារជាសេនាធិការក្នុងការអនុវត្តកម្មវិធីនេះ។

ត្រូវបានបង្កើតអង្គភាពប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈ ដើម្បីសម្របសម្រួលអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ៥._** លក្ខណៈវិនិច្ឆ័យ

ត្រូវបានកំណត់លក្ខណៈវិនិច្ឆ័យ សម្រាប់ទទួលស្គាល់ជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ដូចខាងក្រោម៖

១. ជានីតិបុគ្គលដែលបានចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបានបង្ហាញថាមានអនុលោមភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការនាំចេញ ការនាំចូល និងការឆ្លងកាត់ ព្រមទាំងមិនបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរណាមួយក្នុងរយៈពេលបីឆ្នាំចុងក្រោយ គិតត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។

២. មានប្រព័ន្ធគ្រប់គ្រង កាន់កាប់ និងថែរក្សា បញ្ជីស្នាមគណនេយ្យ កំណត់ត្រា ឯកសារនាំចូល ឯកសារនាំចេញ ឯកសារឆ្លងកាត់ ឯកសារពាណិជ្ជកម្ម ឯកសារគាំទ្រ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតបានច្បាស់លាស់ ត្រឹមត្រូវ និងអាចផ្ទៀងផ្ទាត់បាន។

៣. មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ប្រតិបត្តិការធុរកិច្ចរបស់ខ្លួន និងសម្រាប់បំពេញកាតព្វកិច្ចពន្ធនានា ដូចជា មិនធ្លាប់ជំពាក់បំណុលពន្ធនិងអាករហួសកាលកំណត់ឬបំណុលផ្សេងទៀតដែលមិនអាចសងបាន និងមិនក្ស័យធនក្នុងរយៈពេលបីឆ្នាំចុងក្រោយគិតត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ ព្រមទាំងបានបង្ហាញថា មានអនុលោមភាពហិរញ្ញវត្ថុស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននិងគោលការណ៍គណនេយ្យដែលទទួលស្គាល់ជាទូទៅក្នុងរយៈពេលបីឆ្នាំចុងក្រោយ។

៤. មានកិច្ចពិគ្រោះយោបល់ កិច្ចសហប្រតិបត្តិការ កិច្ចប្រាស្រ័យទាក់ទង ការផ្លាស់ប្តូរព័ត៌មានជាប្រចាំជាមួយរដ្ឋបាលគយ និងរាយការណ៍ជាលាយលក្ខណ៍អក្សរ ជូនរដ្ឋបាលគយជាបន្ទាន់អំពីការផ្លាស់ប្តូរនានានៅក្នុងក្រុមហ៊ុន ការរកឃើញនូវភាពមិនប្រក្រតីនានា ឬអំពើល្មើសណាមួយ។

៥. ផ្តល់ការអប់រំបណ្តុះបណ្តាលជូន កម្មករ និយោជិត អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងអំពីសន្តិសុខនិងសុវត្ថិភាពនៃរំហូរទំនិញ និងផ្តល់ការហ្វឹកហាត់អំពីការគ្រប់គ្រងគ្រោះមហន្តរាយនិងការត្រៀមលក្ខណៈឆ្លើយតបក្នុងគ្រោះអាសន្ន។

៦. មានការកត់ត្រាជាលាយលក្ខណ៍អក្សរនិងក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នូវសកម្មភាពនាំចេញនាំចូល រំហូរទំនិញ និងការគ្រប់គ្រងក្នុងការចូលប្រើប្រាស់ ការរក្សាការសម្ងាត់ និងការរក្សាទុកនូវទិន្នន័យទាំងនោះប្រកបដោយសុវត្ថិភាព។

៧. មានប្រព័ន្ធរក្សាសន្តិសុខនិងសុវត្ថិភាព លើការលើកដាក់ ការដឹកជញ្ជូន និងការរក្សាទុកទំនិញនាំចូល ទំនិញនាំចេញ និងទំនិញឆ្លងកាត់។

៨. មានប្រព័ន្ធរក្សាសន្តិសុខនិងសុវត្ថិភាព ចំពោះមធ្យោបាយដឹកជញ្ជូន កុងតឺន័រ អាជីវកម្មដ្ឋានឃ្លាំង និងទីកន្លែងសន្និធិទំនិញផ្សេងទៀត។

៩. មានប្រព័ន្ធគ្រប់គ្រងនិងកត់ត្រា សន្តិសុខនិងសុវត្ថិភាព សម្រាប់ បុគ្គលិក កម្មករ និយោជិតនិងភ្ញៀវ ចេញចូលអាជីវកម្មដ្ឋាននិងទីតាំងពាក់ព័ន្ធផ្សេងទៀតរបស់ខ្លួន។

១០.មានប្រព័ន្ធគ្រប់គ្រងនិងកត់ត្រា សន្តិសុខនិងសុវត្ថិភាព សម្រាប់និង/ឬជាមួយ ដៃគូពាណិជ្ជកម្មរបស់ខ្លួន។

១១.មានយន្តការគ្រប់គ្រងគ្រោះមហន្តរាយ គ្រោះអាសន្ន និងឧបទ្ទវហេតុនានា ច្បាស់លាស់និងមាននីតិវិធីត្រៀមបង្ការនិងទប់ស្កាត់ដោះស្រាយបញ្ហាទាំងនោះ ឱ្យបានទាន់ពេលវេលានិងទាន់សភាពការណ៍។

១២.មានយន្តការសវនកម្មផ្ទៃក្នុង ត្រួតពិនិត្យ វិភាគ វាយតម្លៃ កែតម្រូវ និងកែលម្អជាប្រចាំ។

លក្ខណៈវិនិច្ឆ័យខាងលើ អាចប្រែប្រួលទៅតាមប្រភេទអាជីវកម្មរបស់បុគ្គលស្នើសុំនីមួយៗ។

នីតិវិធីប្រតិបត្តិស្តង់ដា សម្រាប់ការផ្តល់សុពលភាពនិងកម្រងសំណួរវាយតម្លៃសម្រាប់ការស្នើសុំទទួលស្គាល់ជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ត្រូវកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ៦.-** អត្ថប្រយោជន៍នៃកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត

ត្រូវបានផ្តល់ការលើកទឹកចិត្តជូនប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត នូវអត្ថប្រយោជន៍នានា ដូចខាងក្រោម៖

១.ទទួលបានអាទិភាពដោយមិនចាំបាច់រង់ចាំជួរតាមលំដាប់លំដោយ ទាំងការរៀបចំឯកសារនិងការបំពេញបែបបទបញ្ជេញទំនិញពីគយ ប៉ុន្តែត្រូវអនុវត្តគោលការណ៍មកមុនផ្ដល់សេវាមុនក្នុងចំណោមប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតដូចគ្នា។

២.លើកលែងនីតិវិធីនៃការផ្ទៀងផ្ទាត់អនុលោមភាពនានាមុនពេលបំពេញបែបបទបញ្ចេញទំនិញពីគយ ដូចជា ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ ឬវិញ្ញាបនបត្រប្រភពដើមកំណើតទំនិញ ជាដើម។

៣.លើកលែងកាតព្វកិច្ចអមលិខិតអនុញ្ញាតដឹកជញ្ជូនជាមួយទំនិញនិងមធ្យោបាយដឹកជញ្ជូន។

៤.ទទួលបានការអនុញ្ញាតឱ្យបំពេញបែបបទបញ្ចេញទំនិញពីគយមុនពេលទំនិញមកដល់។

៥.ទទួលបានការអនុញ្ញាតឱ្យបំពេញបែបបទបញ្ចេញទំនិញពីគយនៅចុងទី ដូចជា នៅភណ្ឌាគារគយមានដែនកំណត់ នៅសន្និធិគយបណ្ដោះអាសន្ន ឬនៅអាជីវកម្មដ្ឋានរបស់សាមីក្រុមហ៊ុនផ្ទាល់។

៦.លើកលែងការស្នើសុំលិខិតអនុញ្ញាតនៅទីចាត់ការកណ្ដាលនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដោយគ្រាន់តែស្នើសុំនាំចូល នាំចេញ ឬឆ្លងកាត់ ដោយផ្ទាល់នៅការិយាល័យបំពេញបែបបទបញ្ចេញទំនិញពីគយ។

៧.ទទួលបានអាទិភាពក្នុងការបំពេញបែបបទបញ្ចេញទំនិញពីគយផ្សេងទៀត ដែលនឹងកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

៨.លើកលែងកាតព្វកិច្ចនៃការឆ្លងម៉ាស៊ីនស្កេន។ ក្នុងករណីចាំបាច់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាអាចតម្រូវឱ្យឆ្លងម៉ាស៊ីនស្កេនដោយផ្អែកតាមគោលការណ៍នៃការគ្រប់គ្រងហានិភ័យ។

៩.កាត់បន្ថយការត្រួតពិនិត្យរូបវន្ត ស្របតាមគោលការណ៍នៃការគ្រប់គ្រងហានិភ័យ។

១០.ទទួលបានការអនុញ្ញាតឱ្យជំពាក់បែបបទគយចំពោះការនាំចេញ ការនាំចូល និងការឆ្លងកាត់ដោយពុំតម្រូវឱ្យតម្កល់និមុត្តិធានា។

១១.ទទួលបានការអនុញ្ញាតឱ្យយកទំនិញ មុនពេលបង់ពន្ធនិងអាករក្នុងរយៈពេលកំណត់មួយ។

១២.ទទួលបានអត្ថប្រយោជន៍នានាពីការចុះកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកជាមួយរដ្ឋបាលគយប្រទេសផ្សេងទៀត។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាអាចកំណត់អត្ថប្រយោជន៍ផ្សេងៗបន្ថែមទៀតតាមប្រភេទនៃអាជីវកម្មរបស់ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតនីមួយៗ។

**ប្រការ៧.-** សិទ្ធិរបស់ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត

ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតមានសិទ្ធិដូចខាងក្រោម៖

១.ទទួលបានអត្ថប្រយោជន៍នានាដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះ។

២. ធ្វើទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអង្គភាពគយនិងរដ្ឋាករនានាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

៣. ធ្វើបណ្ដឹងតវ៉ា ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន រួមទាំងការតវ៉ា ចំពោះការបដិសេធ ការព្យួរ ឬការដកហូតវិញ្ញាបនបត្រប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

៤. ស្នើសុំឱ្យមានអ្នកតំណាងក្នុងការរៀបចំសំណុំឯកសារស្នើសុំវិញ្ញាបនបត្រ។

៥. ស្នើសុំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាផ្ដល់កិច្ចពិភាក្សាពិគ្រោះយោបល់។

៦. ប្រើប្រាស់និមិត្តសញ្ញា ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

៧. ស្នើសុំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រៀបចំ កិច្ចប្រជុំ វគ្គបណ្ដុះបណ្ដាល ឬសិក្ខាសាលានានាពាក់ព័ន្ធនឹងកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

៨. ចូលរួម បញ្ចេញមតិ យោបល់ផ្សេងៗ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

**ប្រការ៨.-** បែបបទនិងនីតិវិធីនៃការស្នើសុំ

បុគ្គលដែលមានបំណងស្នើសុំ ការទទួលស្គាល់ជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ត្រូវបំពេញកម្រងសំណួរវាយតម្លៃនិងត្រូវដាក់ពាក្យស្នើសុំមកអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដោយភ្ជាប់ជាមួយនូវឯកសារគាំទ្រនិងឯកសារសំអាងនានា។

ក្នុងរយៈពេលយ៉ាងយូរ ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីទទួលបានពាក្យស្នើសុំ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលត្រូវបានបំពេញគ្រប់គ្រាន់និងត្រឹមត្រូវ។ ក្នុងករណីព័ត៌មាននិងឯកសារភ្ជាប់មិនត្រឹមត្រូវ និង/ ឬ មិនគ្រប់គ្រាន់ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវជូនដំណឹងដល់បុគ្គលស្នើសុំដើម្បីធ្វើការកែតម្រូវឬបំពេញបន្ថែម។ ក្នុងករណីចាំបាច់ រយៈពេលនេះអាចពន្យារបាន ៣០ (សាមសិប) ថ្ងៃបន្ថែមទៀត។

បែបបទនិងនីតិវិធីលម្អិតនៃការស្នើសុំការទទួលស្គាល់ជាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ព្រមទាំងកម្រងសំណួរវាយតម្លៃនិងឯកសារតម្រូវ ត្រូវកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ៩.-** ការផ្ដល់និងការបដិសេធ

ក្នុងរយៈពេលយ៉ាងយូរ ១២០ (មួយរយម្ភៃ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំនិងកម្រងសំណួរវាយតម្លៃត្រឹមត្រូវនិងគ្រប់គ្រាន់ និងបន្ទាប់ពីបានចុះដល់អាជីវកម្មដ្ឋានរបស់បុគ្គលស្នើសុំដើម្បីផ្ទៀងផ្ទាត់សុពលភាពនិងលក្ខណៈសម្បត្តិស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវឆ្លើយតបបុគ្គលស្នើសុំអំពីការផ្ដល់ឬការបដិសេធវិញ្ញាបនបត្រប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។ ក្នុងករណីចាំបាច់ រយៈពេលនេះអាចពន្យារបាន ៦០ (ហុកសិប) ថ្ងៃបន្ថែមទៀត។

ការបដិសេធ ផ្តល់វិញ្ញាបនបត្រប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ជូនបុគ្គលស្នើសុំ ដែលមិនបំពេញគ្រប់លក្ខណៈសម្បត្តិនិងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ត្រូវមានបញ្ជាក់ពីមូលហេតុនៃការបដិសេធ។

**ប្រការ១០.-** ការព្យួរឬការដកហូតវិញ្ញាបនបត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានសិទ្ធិ ព្យួរ ឬដកហូត វិញ្ញាបនបត្រប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ឬវាយតម្លៃលក្ខណៈសម្បត្តិឡើងវិញ ក្នុងករណីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

១.លែងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ។

២.រកឃើញថាបានផ្តល់ព័ត៌មានមិនពិតឬប្រើប្រាស់ឯកសារក្លែងក្លាយ។

៣.ប្រព្រឹត្តអំពើល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១១.-** កាតព្វកិច្ចរបស់បុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត

បុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតមានកាតព្វកិច្ចដូចខាងក្រោម៖

១.បំពេញកម្រងសំណួរវាយតម្លៃ។

២.ផ្តល់ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នូវពាក្យស្នើសុំ និងបំពេញគ្រប់លក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ ដោយភ្ជាប់ជាមួយឯកសារគាំទ្រនិងឯកសារសំអាងផ្សេងៗទៀតសម្រាប់ការផ្ទៀងផ្ទាត់។

៣.ត្រូវធានាអះអាងជាលាយលក្ខណ៍អក្សរឬតាមទម្រង់អេឡិចត្រូនិកផ្សេងទៀត ថា ព័ត៌មានស្នើសុំវិញ្ញាបនបត្រនិងឯកសារគាំទ្រដែលខ្លួនបានបំពេញទោះតាមវិធីណាក៏ដោយនិងដោយអ្នកតំណាងក៏ដោយ គឺពិតជាព័ត៌មានត្រឹមត្រូវនិងមិនក្លែងក្លាយ។

៤.លាតត្រដាងនិងបង្ហាញនូវឯកសារពាក់ព័ន្ធទាំងអស់ដោយមិនបង្វែបង្វង់ តាមការស្នើសុំរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដូចជា ព័ត៌មានអំពីប្រតិបត្តិការធុរកិច្ច ការនាំចេញ នាំចូល ទំហំពាណិជ្ជកម្ម របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម ការទូទាត់ទំនិញនាំចូល របាយការណ៍ផលិត ឬរបាយការណ៍លក់ទំនិញជាដើម។

៥.បង្កើតឱ្យមានការិយាល័យឬចាត់បុគ្គលិក ទទួលបន្ទុកទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

៦. ផ្តល់ព័ត៌មានជាប្រចាំជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាអំពីការផ្លាស់ប្តូរនានា។

៧. អនុញ្ញាតនិងផ្តល់កិច្ចសហការសម្របសម្រួលជូនមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច ចុះផ្ទៀងផ្ទាត់សុពលភាពនិងចុះត្រួតពិនិត្យអនុលោមភាពដល់អាជីវកម្មដ្ឋាន ឬទីកន្លែងពាក់ព័ន្ធនានារបស់បុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១២.-** សុពលភាពវិញ្ញាបនបត្រ

វិញ្ញាបនបត្រប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតមានសុពលភាពរយៈពេល ៣(បី) ឆ្នាំ។

ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតអាចដាក់ពាក្យស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ខែ មុនពេលផុតសុពលភាពវិញ្ញាបនបត្រ ដោយភ្ជាប់ជាមួយឯកសារដែលមានការកែប្រែឬផ្លាស់ប្ដូរនានានិងឯកសារគាំទ្រផ្សេងទៀត។

បែបបទនិងនីតិវិធីលម្អិត នៃការស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ត្រូវកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ១៣.-** ការតាមដាននិងត្រួតពិនិត្យ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃឡើងវិញជាប្រចាំនូវអនុលោមភាពរបស់ប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

បែបបទនិងនីតិវិធីលម្អិតនៃយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ត្រូវកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ១៤.-** និមិត្តសញ្ញាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត

ត្រូវបានបង្កើតនិមិត្តសញ្ញាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

ការរចនា អត្ថន័យ និងខ្លឹមសារ នៃនិមិត្តសញ្ញាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

បុគ្គលណាប្រើប្រាស់និមិត្តសញ្ញាប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ដោយគ្មានការអនុញ្ញាតពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១៥.-** បណ្ដឹងតវ៉ា

មុនពេល បដិសេធ ព្យួរ ឬដកហូតវិញ្ញាបនបត្រ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាអាចផ្ដល់ការប្រឹក្សាយោបល់ឬសវនាការជាមួយបុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត។

បុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ដែលមិនពេញចិត្តនឹងការបដិសេធ ការព្យួរ ឬការដកហូតវិញ្ញាបនបត្រ អាចដាក់ពាក្យបណ្ដឹងតវ៉ាទៅ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាតបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចស្ដីពីការបដិសេធ ការព្យួរ ឬការដកហូតវិញ្ញាបនបត្រ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវពិនិត្យ ដោះស្រាយ សម្រេច ឬមានវិធានការឆ្លើយតបលើពាក្យបណ្តឹងរបស់បុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ក្នុងរយៈពេលមិនលើសពី ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលពាក្យបណ្តឹង។

បុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ដែលមិនពេញចិត្តចំពោះការសម្រេច ឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ១៦._** បណ្តឹងតវ៉ាទៅតុលាការ

បុគ្គលស្នើសុំឬប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត ដែលមិនពេញចិត្តចំពោះការសម្រេចរបស់គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ អាចដាក់ពាក្យបណ្តឹងតវ៉ា ទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ១៧._** ការអនុវត្ត

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ១០ រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី - ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ